៣



# សិទ្ធិបង្ហាញភស្តុតាង

## សិទ្ធិហៅ និងសាកសួរសាក្សី

## និយមន័យ

រាល់សេចក្តីសម្រេចរបស់តុលាការត្រូវតែផ្អែកលើភស្តុតាង ដែលបានបង្ហាញនៅអំឡុងពេលជំនុំជម្រះ។ ហេតុដូច្នេះ នេះជាការសំខាន់ដែលភាគីនីមួយៗត្រូវបានផ្តល់ឱកាសដើម្បីបង្ហាញភស្តុតាង និងហៅសាក្សីនានាក្នុងការគាំទ្រដល់សំណុំរឿងរបស់ខ្លួន និងសួរដេញដោលសាក្សី ដែលត្រូវបានហៅមកដោយភាគីដទៃ ដើម្បីតទល់នឹងភស្តុតាងដែលពួកគេមិនទទួលយក។

សិទ្ធិបង្ហាញភស្តុតាងរួមមាន សិទ្ធិហៅ និងសាកសួរសាក្សី ផ្តល់ឱ្យភាគីជនជាប់ចោទនូវអំណាចស្របច្បាប់ក្នុងការបង្ហាញភស្តុតាង ក៏ដូចជាការហៅ និងសាកសួរសាក្សី ដូចព្រះរាជអាជ្ញាដែរ។

ការហៅសាក្សី៖ ជនជាប់ចោទអាចទាមទារឱ្យមានការចូលរួមរបស់សាក្សី និងអ្នកជំនាញដើម្បីធ្វើសក្ខីកម្មគាំទ្រខ្លួន។

ការសាកសួរសាក្សី៖ ភាគីនីមួយៗរួមមានជនជាប់ចោទអាចសួរសាក្សីរបស់ខ្លួន ដើម្បីគាំទ្រសំណុំរឿងរបស់ខ្លួន។

ការសួរដេញដោលសាក្សី៖ ភាគីនីមួយៗ រួមទាំងជនជាប់ចោទ អាចសាកសួរសាក្សីដែលបង្ហាញដោយភាគីផ្សេងទៀត ដើម្បីជំទាស់នឹងសក្ខីកម្មរបស់ពួកគេ។

## ក្របខ័ណ្ឌច្បាប់

### ច្បាប់អន្តរជាតិ



សិទ្ធិបង្ហាញភស្តុតាងត្រូវបានធានាដោយមាត្រា ១៤ (៣)(ង) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលចែងថា "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិសួរចម្លើយ ឬសុំឱ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួនដើម្បីសួរចម្លើយក្នុងនាមខ្លួនក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក។"

### ច្បាប់ជាតិ



សិទ្ធិបង្ហាញភស្តុតាងត្រូវបានការពារដោយមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ដែលចែងថា "ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ" ហើយសិទ្ធិនេះក៏បានបញ្ញត្តិក្នុងមាត្រាមួយចំនួននៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងមាត្រា ៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

# សារសំខាន់

## សិទ្ធិហៅ និងសាកសួរសាក្សី




ជួយដល់តុលាការក្នុងការវាយតម្លៃការដេញដោលផ្សេងៗដែលបានត្រូវបង្ហាញ និងធ្វើសេចក្ដីសម្រេចដោយផ្អែកលើភស្តុតាងពាក់ព័ន្ធ។



ធានាដល់ជនជាប់ចោទនូវការការពារប្រកបដោយប្រសិទ្ធភាព។




ធានាដល់ការគោរពគោលការណ៍ស្មើភាពគ្នា ដែលតម្រូវឱ្យភាគីទាំងអស់ត្រូវបានប្រព្រឹត្តក្នុងវិធីដែលធានានូវសមភាពនៅដំណាក់កាលនៃសវនាការ។

# ដែនកំណត់



សិទ្ធិហៅ និងសាកសួរសាក្សីជាសិទ្ធិដែលមានដែនកំណត់ មានន័យថា ជនជាប់ចោទមិនអាចទទួលបានវត្តមានជាក់លាក់របស់សាក្សីនោះទេ។ សិទ្ធិនេះផ្ដល់សិទ្ធិឱ្យជនជាប់ចោទហៅសាក្សី ដែលសក្ខីកម្មរបស់ពួកគេពាក់ព័ន្ធនឹងការការពារក្ដីរបស់ខ្លួន និងដើម្បីមានឱកាសគ្រប់គ្រាន់ក្នុងការសួរសាក្សី ដែលប្រឆាំងនឹងខ្លួន។

នេះមានន័យថា ប្រសិនបើជនជាប់ចោទចង់ហៅសាក្សីណាមួយជាក់លាក់ជំនួសខ្លួន គេត្រូវពន្យល់ប្រាប់តុលាការពីមូលហេតុថាមានសារសំខាន់សម្រាប់សំណុំរឿង។



ទោះបីជាយ៉ាងនេះក្ដី ការរំលោភបំពានសិទ្ធិរបស់ជនជាប់ចោទនឹងកើតឡើង ប្រសិនបើតុលាការអនុញ្ញាតឱ្យព្រះរាជអាជ្ញាអញ្ជើញសាក្សីសំខាន់ ប៉ុន្តែបដិសេធចំពោះការអញ្ជើញសាក្សីសំខាន់ដូចគ្នាដែលបានស្នើដោយជនជាប់ចោទ។

ខែកញ្ញា ឆ្នាំ២០២២

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

Sweden Sverige

People Change the World Diakonia

CC BY NC SA